អំពីរោគ...របេង

# Ethambutol (EMB)

**ថ្នាំ Ethambutol (EMB)** គឺជាថ្នាំពេទ្យម្យ៉ាង បានប្រើដើម្បីព្យាបាលរោគរបេង (TB)។ EMIB គឺជាថ្នាំគ្រាប់មូលសំប៉ែតពណ៌ស (100mg, 400 mg) ។

**☐ អ្នកគួរតែលេបថ្នាំ EMB _____ គ្រាប់ រៀងរាល់ថ្ងៃ ។**

**☐ អ្នកគួរតែលេបថ្នាំ EMB _____ គ្រាប់ នៅថ្ងៃទាំងនេះ**

________________________________________

________________________________________

________________________________________

- ត្រូវលេបថ្នាំនេះនៅពេលដូចៗគ្នា ជារៀងរាល់ថ្ងៃ ។
- បើអ្នកខានលេបមួយដង ត្រូវលេបវាយ៉ាងឆាប់រហ័សបំផុត នៅពេលអ្នកនឹកឃើញ ប៉ុន្តែ**ចូរ**កុំលេបវាឡើយ បើវានៅថ្ងៃដូចគ្នានឹងកំរិតដែលអ្នកត្រូវលេបជាបន្ទាប់ទៀត ។
- ចូរកុំលេបពីរកំរិតជួបគ្នា នៃថ្នាំ INH ដើម្បីបង្គ្រប់ចំនួនដែលខានលេប ។
- ត្រូវលេបថ្នាំនេះ ជារៀងដរាប ដូចគ្រូពេទ្យបានប្រាប់ ។

## ត្រូវប្រាប់គ្រូពេទ្យ ឬគិលានុបដ្ឋាក បើសិនជាអ្នក :

- មានជំងឺថ្លើម ជំងឺវក្កំ(តម្រងនោម) ឬមានបញ្ហារោគាផ្សេងទៀត
- លេបថ្នាំពេទ្យដែលមានវេជ្ជបញ្ជា
- លេបថ្នាំអាចទិញបាន-ពុំបាច់មាន-សំបុត្រពេទ្យ
- ចាប់ផ្តើមលេបថ្នាំថ្មីអ្វីមួយ ក្នុងកំឡុងពេលការព្យាបាលនេះ
- កំពុងមានផ្ទៃពោះ ឬបំរុងនឹងមានផ្ទៃពោះ
- កំពុងបំបៅដោះកូន
- មានប្រតិកម្មនឹងវត្ថុធាតុ(អាឡ៊ែរជី)
- ផឹកស្រា ឬប្រើគ្រឿងញៀន រៀងរាល់ថ្ងៃ ឬមានចំនួនច្រើន

## ការដែលត្រូវឃ្លាំមើល ក្នុងកាលដែលកំពុងលេបថ្នាំ EMB :

មនុស្សភាគច្រើនអាចលេបថ្នាំ EMB បាន ដោយពុំមានបញ្ហាអ្វីឡើយ ប៉ុន្តែថ្នាំពេទ្យអ្វីមួយសុទ្ធតែអាចបណ្តាលឲ្យមានប្រតិកម្មរាយរង ។

បើអ្នកមានរោគសញ្ញាអ្វីមួយនៅខាងក្រោម ត្រូវឈប់លេបថ្នាំនោះ ហើយត្រូវទូរស័ព្ទទៅគិលានុបដ្ឋាក ឬគ្រូពេទ្យ នៅមន្ទីរព្យាបាលរោគរបេងយ៉ាងឆាប់រហ័សបំផុត ។ **ចូរកុំរង់ចាំរហូតដល់ពេលការណាត់ជួបរបស់អ្នក នៅលើកក្រោយទៀតឲ្យសោះ ។**

- មើលពណ៌មិនស្គាល់ច្បាស់លាស់
- ប្រែប្រួលក្នុងការមើលឃើញ មានបញ្ហាក្នុងការអានអក្សរ
- ភ្នែកក្រហម (ភ្នែកពណ៌ក្រហម)
- ឈឺក្បាល
- ឈឺសន្លាក់ឆ្អឹង
- រមួលពោះ ក្អួតចង្អោរ ឬ បាត់បង់ការឃ្លានអាហារ
- គ្រុន
- អស់កំឡាំងកំហែងណាស់ ឬ ខ្សោយកំឡាំង
- កន្ទួល រមាស់ ឬ ផ្តួតសាច់
- ទឹកនោមសម្បុរស្រអាប់
- លឿងស្បែក ឬ បើផ្នែកសៗនៃភ្នែកក្លាយជាពណ៌លឿង
- លាមកសម្បុរស ប្រផេះ ឬ សម្បុរដាំដែង (ការបន្ទោលាមក)

ថ្នាំ EMIB គួរតែបានលេបជាមួយនឹងអាហារ ។

ការផឹកស្រា ឬលេបថ្នាំពេទ្យផ្សេងទៀត ឬប្រើគ្រឿងញៀន អាចបង្កើនភាពគ្រោះថ្នាក់របស់អ្នក នូវប្រតិកម្មរាយរងចំពោះថ្នាំ EMB ។ **ត្រូវដាក់កំរិតការផឹកស្រា និងការប្រើឱសថ ក្នុងកាលកំពុងតែលេបថ្នាំនេះ។**

អ្នកនឹងត្រូវទៅជួបគ្រូពេទ្យ ឬគិលានុបដ្ឋាក ជារៀងរាល់ខែ ក្នុងកាលដែលអ្នកកំពុងលេបថ្នាំ EMB ។ បើអ្នកមានសំណួរអ្វី ស្តីអំពីរោគរបេង ឬថ្នាំ EMB សូមទាក់ទងទៅគិលានុបដ្ឋាក នៅមន្ទីរព្យាបាលរោគរបេង ។

Massachusetts Department of Public Health
Division of Tuberculosis Prevention and Control
www.mass.gov/dph/cdc/tb/

ទូរស័ព្ទ : ______________________________